# **ដំណឹងជ្រើសរើសបុគ្គលិក**

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សីលានិធិ លីមីធីត** ទទួលបានអាជ្ញាប័ណ្ណអចិន្ត្រៃពីធនាគារជាតិ នៃកម្ពុជា កំពុងបម្រើ សេវាកម្មមីក្រូហិរញ្ញវត្ថុនៅក្នុង ២៥សាខា ខេត្ត-ក្រុង-ស្រុក ដែលកំពុងបម្រើសេវា កម្មឥណទាន និង សន្សំ នៅតាមបណ្តា ខេត្តកណ្តាល ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តកំពង់ចាម។ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **សីលានិធិ លីមីធីត** ត្រូវការជ្រើសរើស **បុគ្គលិកជំនួយការ ការិយាល័យ**(**សន្តិសុខ**)ចំនួន០១នាក់ សម្រាប់បំរើការងារនៅ **សាខាខណ្ឌពោធិ៍សែនជ័យ** ។

## ១. ***ភារកិច្ច និងការទទួលខុសត្រូវ:***

បុគ្គលិកសន្តិសុខ ត្រូវទទួលខុសត្រូវក្នុងការយាមកាមប្រចាំការនៅក្នុងសាខាដែលមានភារៈកិច្ច និងការ ទទួលខុសត្រូវខាងក្រោម:

១. ថែរក្សាសុវត្ថិភាពនៅក្នុងសាខាឲ្យបានល្អនិងថែរក្សាទ្រព្យសម្បត្តិទាំងអស់របស់សាខាឲ្យបានគង់វង្ស។
២. ថែរក្សាអនាម័យ នៅក្នុងសាខា និងសម្ភារៈ បរិក្ខារប្រើប្រាស់ផ្សេងៗរបស់សាខាឲ្យមាន អនាម័យល្អ។
៣. កត់ត្រារាល់ព័ត៌មានរបស់ភ្ញៀវដែលចេញ និងចូលមកទំនាក់ទំនងជាមួយសីលានិធិ។
៤. ត្រួតពិនិត្យ និងថែទាំ ប្រព័ន្ធទឹក/ភ្លើង និងទូរសព្ទ។
៥. ជួសជុលសម្ភារៈប្រើប្រាស់របស់សាខា និងថតចម្លងឯកសារ។

## ២. ***លក្ខណៈសម្បត្តិដែលបេក្ខជនត្រូវមាន:***

១. បេក្ខជនត្រូវជា ជនជាតិខ្មែរ។
២. បេក្ខជនត្រូវមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ។
៣. បញ្ចប់ការសិក្សាត្រឹមថ្នាក់ទី១២ ឬសញ្ញាបត្រដែលមានតម្លៃស្មើ
៤. ជាមនុស្ស ស្មោះត្រង់ និងមានការទទួលខុសត្រូវខ្ពស់ចំពោះការងារ។
៥. មានសុខភាពល្អ និងកាយសម្បទាមាំមួន។
៦. មានអត្តសញ្ញាណប័ណ្ណច្បាស់លាស់ និងមិនធ្លាប់មានជាប់ពិរុទ្ធ។
៧. ជាមនុស្សម៉ឺងម៉ាត់ និងហ្មត់ចត់នៅក្នុងការងារ។

បេក្ខជនដែលមានចំណាប់អារម្មណ៍លើការងារនេះ សូមភ្ជាប់នូវរូបថតបច្ចុប្បន្ន ៤ x ៦ ចំនួន ៣សន្លឹក ពាក្យសុំចូលបម្រើការងារ ប្រវត្តិរូបសង្ខេប១ច្បាប់ ថតចម្លងសៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណ និងឯកសារ ផ្សេងៗ ទៀតមកកាន់ការិយាល័យកណ្តាល ផ្ទះលេខ ១SF ២SF ផ្លូវលេខ ៥១៦ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឬ គ្រប់ការិយាល័យ សាខា ខេត្ត ក្រុង នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ សីលានិធិ។

ចាប់ទទួលពាក្យសុំបម្រើការងារ ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ និងឈប់ទទួលពាក្យនៅថ្ងៃ ទី២៦ ខែកញ្ញា ឆ្នាំ២០១៤ វេលាម៉ោង ៥ ល្ងាច។

ព័ត៌មានលំអិត សូមទំនាក់ទំនងទូរស័ព្ទលេខ៖ ០១០ ៨៨៨ ៨៧៦ / ០២៣ ៩៩០ ២២៥